## សមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលលេខ២១៤ សសរ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីការចាត់តាំងសមាសភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត
- យោងកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា
- បានឃើញសេចក្ដីណែនាំរបស់រាជរដ្ឋាភិបាលលេខ០៤ សណន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្ដីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន
- យោងតាមសំណូមពរចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ .‒**

ត្រូវបានចាត់តាំង ឯកឧត្តម **ហោ ស៊ីឌុត្ថា** ទីប្រឹក្សារាជរដ្ឋាភិបាល ជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត។

**ប្រការ២ .‒**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពត អភិបាលនៃគណៈអភិបាលខេត្តកំពត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១កើត ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០២៥

**គប. នាយករដ្ឋមន្ត្រី**
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.១៥៥......សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការអនុគ្រោះពន្ធកាត់ទុកចំពោះក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

**សម្រេច**

**ប្រការ១**.-

ប្រកាសនេះ មានគោលបំណងកាត់បន្ថយបន្ទុកចំណាយទាក់ទិននឹងពន្ធកាត់ទុករបស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក ដើម្បីជាការចូលរួមគាំទ្រដល់វិស័យទេសចរណ៍។

**ប្រការ២**.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក។

**ប្រការ៣**.-

១- បន្ថយអត្រាពន្ធកាត់ទុកមកត្រឹម ២ (ពីរ) ភាគរយ ចំពោះការទូទាត់របស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ដូចខាងក្រោម៖

ក- ថ្លៃជួលយន្តហោះ (Aircraft Rental)

ខ- សេវាថែទាំ និងជួសជុលយន្តហោះ (Maintenance and Overhaul)

គ- ថ្លៃជំនួយបច្ចេកទេសពីក្រៅប្រទេស (Overseas Technical Assistance)

ឃ- ថ្លៃចុះចតនៅអាកាសយានដ្ឋានក្រៅប្រទេស (Overseas Airport Charge)

ង- សេវាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគាំទ្រផ្សេងៗ (IT Shared Service Cost)

ច- ថ្លៃអាជ្ញាបណ្ណម៉ាក និងពាណិជ្ជសញ្ញា (Brand Licensing Fee)

ឆ- កម្រៃជើងសារលើសេវាកក់សំបុត្រតាមប្រព័ន្ធអនឡាញ (Online Ticket Booking System)

ជ- សេវាលើការបណ្តុះបណ្តាលសមត្ថភាព (Training by Overseas Vendor)

ឈ- ថ្លៃប្រព័ន្ធមេសម្រាប់ការគ្រប់គ្រងប្រតិបត្តិការ (Centralized System Shared Cost)

ញ- ថ្លៃអាជ្ញាបណ្ណសម្រាប់ប្រព័ន្ធគាំទ្រនានា (System License Fee)

២- បន្ថយអត្រាពន្ធកាត់ទុកមកត្រឹម ១០ (ដប់) ភាគរយ ចំពោះការទូទាត់របស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន ដូចខាងក្រោម៖

ក- ថ្លៃសេវាគ្រប់គ្រងផ្សេងៗ (Management Service Fee)

ខ- ថ្លៃសេវាផ្សេងៗ (Other Services)

៣- ការអនុគ្រោះដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃប្រការនេះ មានរយៈពេល ៤ (បួន) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៨។

**ប្រការ៤**.-

ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកទាំងអស់ត្រូវអនុវត្តនូវកាតព្វកិច្ច ដូចខាងក្រោម៖

១- ត្រូវដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែនិងប្រចាំឆ្នាំ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធតាមអនឡាញ (e-Filing) របស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- ត្រូវកាន់ កត់ត្រា និងថែរក្សាឯកសារបញ្ជីកាគណនេយ្យនិងព័ត៌មានដែលទាក់ទិននឹងសកម្មភាពអាជីវកម្ម ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

**ប្រការ៥**.-

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៩២៥ សហវ.ប្រក.អាពស

# ប្រកាស
## ស្តីពី
## ភាគពុកិច្ចសារពើពន្ធចំពោះសកម្មភាពអាជីវកម្មដឹកជញ្ជូនតាមផ្លូវអាកាស

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ស្តីពីអាករលើតម្លៃបន្ថែម
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ស្តីពីការកែសម្រួលមាត្រា៣ នៃអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ អាករពិសេសលើទំនិញនិងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីសម្រាប់អនុវត្តពន្ធលើប្រាក់ចំណូល អាករពិសេស និងអាករលើតម្លៃបន្ថែម ចំពោះអ្នកជាប់ពន្ធដែលប្រកបអាជីវកម្មដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស។

**ប្រការ២ ._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធនិវាសនជននិងអ្នកជាប់ពន្ធអនិវាសនជន ដែលប្រកបអាជីវកម្មដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- ការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស សំដៅដល់៖

ក- ការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសក្នុងស្រុក ដែលចេញពីកន្លែងមួយទៅកន្លែងមួយទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ- ការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសជាអន្តរជាតិ ក្នុងករណីដែលការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញនោះត្រូវបានធ្វើឡើង៖

- ពីកន្លែងមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា
- ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា មកកន្លែងមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ពីកន្លែងមួយនៅក្រៅព្រះរាជាណាចក្រកម្ពុជា ទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

២- សហគ្រាសដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស សំដៅដល់ សហគ្រាសដែលប្រើប្រាស់យន្តហោះ ឬមធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាសដទៃទៀត សម្រាប់ដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញ ក្នុងគោលដៅអាជីវកម្ម ដែលរួមមាន៖

ក- សហគ្រាសនិវាសនជន គឺជាសហគ្រាសដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ដែលត្រូវបានបង្កើតឬត្រូវបានគ្រប់គ្រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ- សហគ្រាសអនិវាសនជន គឺជាសហគ្រាសដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ដែលត្រូវបានបង្កើតឬត្រូវបានគ្រប់គ្រងនៅក្រៅព្រះរាជាណាចក្រកម្ពុជា។ សម្រាប់គោលដៅនៃវាក្យខណ្ឌនេះ សហគ្រាសអនិវាសនជនអាចធ្វើប្រតិបត្តិការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសតាមរយៈគ្រឹះស្ថានអចិន្ត្រៃយ៍របស់ខ្លួននៅព្រះរាជាណាចក្រកម្ពុជា។

៣- គ្រឹះស្ថានអចិន្ត្រៃយ៍ សំដៅដល់ ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅព្រះរាជាណាចក្រកម្ពុជា សាខារបស់ក្រុមហ៊ុនបរទេស ឬភ្នាក់ងារនិវាសនជនដែលនៅព្រះរាជាណាចក្រកម្ពុជា ដែលតាមរយៈនេះបុគ្គលអនិវាសនជនប្រកបអាជីវកម្មរបស់ខ្លួន។ ពាក្យ គ្រឹះស្ថានអចិន្ត្រៃយ៍ រួមបញ្ចូលផងដែរនូវបណ្ដាញឬរូបភាពទំនាក់ទំនងផ្សេងទៀត ដែលតាមរយៈនេះបុគ្គលអនិវាសនជនធ្វើសកម្មភាពសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា។ បុគ្គលណាមួយអាចត្រូវបានចាត់ទុកជាគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជននៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីបុគ្គលនោះមាននិងអនុវត្តជាប្រចាំនូវសិទ្ធិសម្របសម្រួលដើម្បីឈានដល់ការចុះកិច្ចសន្យា។ គ្រឹះស្ថានអចិន្ត្រៃយ៍ត្រូវចាត់ទុកជានីតិបុគ្គលនិវាសនជនចំពោះតែប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ សាខាឬការិយាល័យ ឬភ្នាក់ងារនិវាសនជន របស់បុគ្គលអនិវាសនជនដែលធ្វើសកម្មភាពដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសចូលឬចេញពីព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកជាគ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជននោះនៅព្រះរាជាណាចក្រកម្ពុជា។ បុគ្គលអនិវាសនជនត្រូវចាត់តាំងបុគ្គលដែលជាគ្រឹះស្ថានអចិន្ត្រៃយ៍ឱ្យចុះបញ្ជីពន្ធដារដើម្បីបំពេញកាតព្វកិច្ចជំនួសមុខឱ្យខ្លួន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៤- ចំណូលដុល សំដៅដល់ ចំណូលដែលបានមកពី៖

ក- ចំណូលពីសកម្មភាពដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស៖

- ថ្លៃដឹកជញ្ជូនអ្នកដំណើរ
- ថ្លៃដឹកជញ្ជូនទំនិញ
- ថ្លៃលើសទម្ងន់
- ថ្លៃប្ដូរប្រភេទកៅអី
- កម្រៃជើងសាដែលពាក់ព័ន្ធនឹងសកម្មភាពដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញ
- ចំណូលបែងចែកពីក្រុមហ៊ុនដើម
- ថ្លៃលក់ម្ហូបអាហារ និងទំនិញលើយន្តហោះ
- ថ្លៃប្ដូរជើងហោះហើរ
- ថ្លៃកែប្រែព័ត៌មានអ្នកដំណើរ
- ថ្លៃមិនបានបង្ហាញខ្លួន
- ចំណូលផ្សេងៗ... វៀរលែងតែកម្រៃសេវាអាកាសចរណ៍ស៊ីវិល កម្រៃសេវាសន្តិសុខអាកាសយានដ្ឋាន និងកម្រៃសេវាអ្នកដំណើរ។

ខ- ចំណូលពីសកម្មភាពផ្សេងៗក្រៅពីការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស៖

- កម្រៃជើងសា
- ការប្រាក់
- ការជួល
- ចំណូលផ្សេងៗ...។

**ប្រការ៤ .-**

អនុលោមតាមមាត្រា៤ នៃច្បាប់ស្ដីពីសារពើពន្ធ អ្នកជាប់ពន្ធនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់ចំណូលចំពោះប្រាក់ចំណូលប្រភពកម្ពុជានិងប្រាក់ចំណូលប្រភពបរទេស និងអ្នកជាប់ពន្ធអនិវាសនជន ត្រូវជាប់ពន្ធលើប្រាក់ចំណូលចំពោះប្រាក់ចំណូលប្រភពកម្ពុជា។

## ជំពូកទី២
## ភាតព្វកិច្ចសារពើពន្ធចំពោះសហគ្រាសនិវាសនជន

**ប្រការ៥ .-**

១- សហគ្រាសនិវាសនជនដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌទី២ នៃប្រការ៣ នៃប្រកាសនេះ ត្រូវមានកាតព្វកិច្ចអនុវត្តពន្ធលើប្រាក់ចំណូលតាមអត្រា ២០ (ម្ភៃ) ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបាន ដោយអនុវត្តវិធាននៃការទទួលស្គាល់ចំណូល និងចំណាយអាចកាត់កងបាន ដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល។

២- ចំពោះការផ្គត់ផ្គង់ទំនិញឬសេវា សហគ្រាសត្រូវកត់ត្រាជាចំណូលនៅពេលចេញវិក្កយបត្រ។ វិក្កយបត្រត្រូវចេញនៅពេលបញ្ជូនទំនិញឬបំពេញសេវា ឬនៅពេលទទួលប្រាក់ប្រសិនបើការទូទាត់ធ្វើឡើងមុនពេលបញ្ជូនទំនិញឬបំពេញសេវា។

៣- ក្នុងករណីទំនិញឬសេវាត្រូវបានយកទៅប្រើប្រាស់ផ្ទាល់ខ្លួន ឬផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយ ឬផ្គត់ផ្គង់ក្រោមតម្លៃពិត សហគ្រាសត្រូវកត់ត្រាជាចំណូលតាមតម្លៃទាបបំផុតដែលបានផ្គត់ផ្គង់ឱ្យអតិថិជនក្នុងខែ នៅពេលដែលទំនិញត្រូវបានបញ្ជូន ឬពេលដែលសេវាត្រូវបានបំពេញ។

**ប្រការ៦ .-**

សកម្មភាពដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស ត្រូវជាប់អាករពិសេសនៅក្នុងខែដែលសេវាត្រូវបានបំពេញតាមអត្រាដូចខាងក្រោម៖

១- ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុងស្រុក៖

ក- ១០ ០០០ (មួយម៉ឺន) រៀល ក្នុងអ្នកដំណើរម្នាក់ក្នុងមួយជើងហោះហើរ សម្រាប់សំបុត្រថ្នាក់សន្សំសំចៃ (Economy Class)។

ខ- ១៦ ០០០ (មួយម៉ឺនប្រាំមួយពាន់) រៀល ក្នុងអ្នកដំណើរម្នាក់ក្នុងមួយជើងហោះហើរ សម្រាប់សំបុត្រថ្នាក់ជំនួញ (Business Class) និងសំបុត្រថ្នាក់ទី១ (First Class)។

២- ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសជាអន្តរជាតិចេញពីព្រះរាជាណាចក្រកម្ពុជា៖

ក- ៤០ ០០០ (បួនម៉ឺន) រៀល ក្នុងអ្នកដំណើរម្នាក់ក្នុងមួយជើងហោះហើរ សម្រាប់សំបុត្រថ្នាក់សន្សំសំចៃ (Economy Class)។

ខ- ៦០ ០០០ (ប្រាំមួយម៉ឺន) រៀល ក្នុងអ្នកដំណើរម្នាក់ក្នុងមួយជើងហោះហើរ សម្រាប់សំបុត្រថ្នាក់ជំនួញ (Business Class)។

គ- ៨០ ០០០ (ប្រាំបីម៉ឺន) រៀល ក្នុងអ្នកដំណើរម្នាក់ក្នុងមួយជើងហោះហើរ សម្រាប់សំបុត្រថ្នាក់ទី១ (First Class)។

**ប្រការ៧ .-**

១- សកម្មភាពដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ត្រូវជាប់អាករលើតម្លៃបន្ថែមនៅពេលចេញវិក្កយបត្រ តាមអត្រាដូចខាងក្រោម៖

ក- ១០ (ដប់) ភាគរយ ចំពោះសេវាដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសក្នុងស្រុក ព្រមទាំងទំនិញឬសេវាដែលបានផ្គត់ផ្គង់ដល់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសក្នុងស្រុកនោះ។

ខ- ០ (សូន្យ) ភាគរយ ចំពោះការផ្គត់ផ្គង់សេវាដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសជាអន្តរជាតិ និងសេវាផ្សេងៗដែលបានផ្គត់ផ្គង់ដល់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសជាអន្តរជាតិ មានជាអាទិ៍ សេវានាំផ្លូវ សេវាចុះចតឬចូលចត និងសេវាផ្តល់ព័ត៌មាន។ ចំពោះការផ្គត់ផ្គង់ប្រេងឥន្ធនៈ ម្ហូបអាហារ និងគ្រឿងប្រើប្រាស់សម្រាប់អ្នកដំណើរដល់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសជាអន្តរជាតិ ត្រូវបានចាត់ទុកជាការផ្គត់ផ្គង់ទំនិញសម្រាប់ប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា។

២- មូលដ្ឋានគិតអាករលើតម្លៃបន្ថែម គឺជាថ្លៃសំបុត្រយន្តហោះឬថ្លៃសេវាដឹកជញ្ជូនទំនិញដែលសហគ្រាសដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសយកពីអតិថិជន ថ្លៃសេវាពាក់ព័ន្ធផ្សេងទៀត រួមបញ្ចូលទាំងពន្ធអាករនានាវៀរលែងតែអាករលើតម្លៃបន្ថែម កម្រៃសេវាអាកាសចរណ៍ស៊ីវិល កម្រៃសេវាសន្តិសុខអាកាសយានដ្ឋាន និងកម្រៃសេវាអ្នកដំណើរ។ ក្នុងការចេញវិក្កយបត្រអាករ សហគ្រាសដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ត្រូវញែកឱ្យដាច់ពីគ្នានូវថ្លៃសំបុត្រយន្តហោះឬថ្លៃសេវាដឹកជញ្ជូនទំនិញ កម្រៃសេវាអាកាសចរណ៍ស៊ីវិល កម្រៃសេវាសន្តិសុខអាកាសយានដ្ឋាន កម្រៃសេវាអ្នកដំណើរ និងកម្រៃដទៃទៀត។

៣- ឥណទានអាករលើធាតុចូលសម្រាប់បម្រើឱ្យសកម្មភាពដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម។

**ប្រការ៨ .-**

សហគ្រាសនិវាសនជនដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌទី២ នៃប្រការ៣ នៃប្រកាសនេះ ត្រូវអនុវត្តពន្ធកាត់ទុកស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

## ជំពូកទី៣
## ភាតព្វកិច្ចសារពើពន្ធចំពោះសហគ្រាសអនិវាសនជន

**ប្រការ៩ .-**

១- សហគ្រាសអនិវាសនជនដូចមានចែងក្នុងវាក្យខណ្ឌ ខ នៃកថាខណ្ឌទី២ នៃប្រការ៣ នៃប្រកាសនេះ ត្រូវមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណូលតាមអត្រា ២០ (ម្ភៃ) ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធប្រភពកម្ពុជា។ ប្រាក់ចំណូលជាប់ពន្ធប្រភពកម្ពុជា ត្រូវកំណត់យកតាមកម្រិតនៃការបែងចែកប្រាក់ចំណូល ស្មើនឹង ១៥ (ដប់ប្រាំ) ភាគរយ នៃចំណូលដុលពីប្រភពកម្ពុជាដែលទទួលបានក្នុងខែ ដោយមិនគិតថាការទូទាត់ត្រូវបានធ្វើឡើងនៅក្នុងឬក្រៅព្រះរាជាណាចក្រកម្ពុជាឡើយ ពីសកម្មភាពដូចខាងក្រោម៖

ក- ការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសចេញពីកន្លែងមួយនៅព្រះរាជាណាចក្រកម្ពុជាទៅកន្លែងមួយទៀតនៅព្រះរាជាណាចក្រកម្ពុជា។

ខ- ការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសចេញពីកន្លែងមួយនៅព្រះរាជាណាចក្រកម្ពុជាទៅកន្លែងមួយទៀតនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលជាគោលដៅដំបូង។

គ- សកម្មភាពផ្សេងទៀតក្រៅពីការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ដែលជាចំណូលប្រភពកម្ពុជា។

**ឧទាហរណ៍ការគណនាពន្ធលើប្រាក់ចំណូលសម្រាប់សហគ្រាសអនិវាសនជន៖**

ពន្ធលើប្រាក់ចំណូល = ចំណូលដុល x ១៥% (កម្រិតនៃការបែងចែកប្រាក់ចំណូល) x ២០% (អត្រាពន្ធលើប្រាក់ចំណូល)។ ក្នុងន័យនេះ អ្នកជាប់ពន្ធត្រូវបង់ពន្ធលើប្រាក់ចំណូល ត្រឹមតែ ៣% នៃចំណូលដុលតែប៉ុណ្ណោះ។

២- សហគ្រាសអនិវាសនជន ត្រូវទទួលស្គាល់ចំណូលតាមលក្ខខណ្ឌដូចខាងក្រោម៖

ក- ចំណូលពីសកម្មភាពដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស នៅពេលដែលការដឹកជញ្ជូនបានកើតឡើង។

ខ- ចំណូលពីសកម្មភាពផ្សេងៗក្រៅពីការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស តាមគោលការណ៍ទូទៅនៃការទទួលស្គាល់ចំណូល ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណូល។

**ប្រការ១០ ._**

សកម្មភាពដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស ត្រូវជាប់អាករពិសេសនៅក្នុងខែដែលសេវាត្រូវបានបំពេញតាមអត្រាដូចខាងក្រោម៖

១- ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសក្នុងស្រុក៖

ក- ១០ ០០០ (មួយម៉ឺន) រៀល ក្នុងអ្នកដំណើរម្នាក់ក្នុងមួយជើងហោះហើរ សម្រាប់សំបុត្រថ្នាក់សន្សំសំចៃ (Economy Class)។

ខ- ១៦ ០០០ (មួយម៉ឺនប្រាំមួយពាន់) រៀល ក្នុងអ្នកដំណើរម្នាក់ក្នុងមួយជើងហោះហើរ សម្រាប់សំបុត្រថ្នាក់ជំនួញ (Business Class) និងសំបុត្រថ្នាក់ទី១ (First Class)។

២- ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសជាអន្តរជាតិចេញពីព្រះរាជាណាចក្រកម្ពុជា៖

ក- ៤០ ០០០ (បួនម៉ឺន) រៀល ក្នុងអ្នកដំណើរម្នាក់ក្នុងមួយជើងហោះហើរ សម្រាប់សំបុត្រថ្នាក់សន្សំសំចៃ (Economy Class)។

ខ- ៦០ ០០០ (ប្រាំមួយម៉ឺន) រៀល ក្នុងអ្នកដំណើរម្នាក់ក្នុងមួយជើងហោះហើរ សម្រាប់សំបុត្រថ្នាក់ជំនួញ (Business Class)។

គ- ៨០ ០០០ (ប្រាំបីម៉ឺន) រៀល ក្នុងអ្នកដំណើរម្នាក់ក្នុងមួយជើងហោះហើរ សម្រាប់សំបុត្រថ្នាក់ទី១ (First Class)។

**ប្រការ១១ ._**

១- សកម្មភាពដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ត្រូវជាប់អាករលើតម្លៃបន្ថែមនៅពេលសេវាត្រូវបានបំពេញតាមអត្រាដូចខាងក្រោម៖

ក- ១០ (ដប់) ភាគរយ ចំពោះសេវាដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសក្នុងស្រុក ព្រមទាំងទំនិញឬសេវាដែលបានផ្គត់ផ្គង់ដល់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសក្នុងស្រុកនោះ។

ខ- ០ (សូន្យ) ភាគរយ ចំពោះការផ្គត់ផ្គង់សេវាដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសជាអន្តរជាតិ និងសេវាផ្សេងៗដែលបានផ្គត់ផ្គង់ដល់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសជាអន្តរជាតិ មានជាអាទិ៍ សេវានាំផ្លូវ សេវាចុះចតឬចូលចត និងសេវាផ្តល់ព័ត៌មាន។ ចំពោះការផ្គត់ផ្គង់ប្រេងឥន្ធនៈ ម្ហូបអាហារ និងគ្រឿងប្រើប្រាស់សម្រាប់អ្នកដំណើរដល់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសជាអន្តរជាតិ ត្រូវបានចាត់ទុកជាការផ្គត់ផ្គង់ទំនិញសម្រាប់ប្រើប្រាស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា។

២- មូលដ្ឋានគិតអាករលើតម្លៃបន្ថែម គឺជាថ្លៃសំបុត្រយន្តហោះឬថ្លៃសេវាដឹកជញ្ជូនទំនិញដែលសហគ្រាសដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសយកពីអតិថិជន ថ្លៃសេវាពាក់ព័ន្ធផ្សេងទៀត រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម កម្រៃសេវាអាកាសចរណ៍ស៊ីវិល កម្រៃសេវាសន្តិសុខអាកាសយានដ្ឋាន និងកម្រៃ

សេវាអ្នកដំណើរ។ ក្នុងការចេញវិក្កយបត្រអាករ សហគ្រាសដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ត្រូវញែកឱ្យដាច់ពីគ្នានូវថ្លៃសំបុត្រយន្តហោះឬថ្លៃសេវាដឹកជញ្ជូនទំនិញ កម្រៃសេវាអាកាសចរណ៍ស៊ីវិល កម្រៃសេវាសន្តិសុខអាកាសយានដ្ឋាន កម្រៃសេវាអ្នកដំណើរ និងកម្រៃដទៃទៀត។

៣- ចំណូលពីសកម្មភាពផ្សេងៗក្រៅពីការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសដែលបានផ្គត់ផ្គង់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម។

៤- ឥណទានអាករលើធាតុចូលសម្រាប់បម្រើឱ្យសកម្មភាពដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម។

**ប្រការ១២ .-**

សហគ្រាសអនិវាសនជនឬគ្រឹះស្ថានអចិន្ត្រៃយ៍របស់អ្នកជាប់ពន្ធអនិវាសនជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានបង់ពន្ធលើប្រាក់ចំណូលដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ មិនតម្រូវឱ្យបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែ ពន្ធអប្បបរមា និងមិនត្រូវឱ្យអនុវត្តពន្ធកាត់ទុកចំពោះប្រាក់ចំណូលប្រភពកម្ពុជាទៀតឡើយ វៀរលែងតែពន្ធកាត់ទុកលើថ្លៃឈ្នួលចលនទ្រព្យនិងអចលនទ្រព្យ និងពន្ធលើប្រាក់បៀវត្សរបស់បុគ្គលនិវាសនជន។

## ជំពូកទី៤
## ការដាក់លិខិតប្រកាសសារពើពន្ធ

**ប្រការ១៣ .-**

សហគ្រាសដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

១- សហគ្រាសនិវាសនជនដូចមានចែងក្នុងវាក្យខណ្ឌ ក នៃកថាខណ្ឌទី២ នៃប្រការ៣ នៃប្រកាសនេះ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗនិងលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំសម្រាប់ឆ្នាំជាប់ពន្ធ និងបង់ប្រាក់ពន្ធអាករទាំងអស់ទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

២- គ្រឹះស្ថានអចិន្ត្រៃយ៍របស់សហគ្រាសអនិវាសនជនដែលធ្វើសកម្មភាពដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ដាក់លិខិតប្រកាសសារពើពន្ធប្រចាំខែ ចំពោះពន្ធលើប្រាក់ចំណូលរបស់បុគ្គលអនិវាសនជនស្របតាមប្រការ៩ នៃប្រកាសនេះ និងបង់ប្រាក់ពន្ធអាករដទៃទៀត ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលប្រាក់ចំណូលសម្រេចបាន ទៅតាមទម្រង់ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

ខ- ដាក់លិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ ទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ តែមិនតម្រូវឱ្យបង់ប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំឡើយ។

៣- ពន្ធលើប្រាក់ចំណូល និងប្រាក់ពន្ធអាករដទៃទៀត ដែលត្រូវបង់តាមកថាខណ្ឌទី២ នៃប្រការនេះ គឺជាបន្ទុករបស់បុគ្គលអនិវាសនជនដែលធ្វើសកម្មភាពដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស។ គ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជនត្រូវមានកាតព្វកិច្ចកាត់ទុកនិងប្រកាសបង់ពន្ធជូនរដ្ឋបាលសារពើពន្ធ។ ក្នុងករណីមានការខកខានមិនបានកាត់ទុក គ្រឹះស្ថានអចិន្ត្រៃយ៍របស់បុគ្គលអនិវាសនជន ជាអ្នកទទួលខុសត្រូវ។

## ជំពូកទី៥
## កិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា

**ប្រការ១៤ ._**

សហគ្រាសដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាសដែលជាសហគ្រាសរបស់ភាគីនៃកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធជាមួយព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមបទប្បញ្ញត្តិទាក់ទិននឹងការដឹកជញ្ជូនអ្នកដំណើរនិង/ឬទំនិញតាមផ្លូវអាកាស និងវិធាននិងនីតិវិធីពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធនិងការចៀសវាងពន្ធ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦ ._**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៨.០២៥.៥៥៣.ប្រ.ក

# ប្រកាស
# ស្តីពី
# ការដកហូតអាជ្ញាបណ្ណនិងជម្រះបញ្ជី
# គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ម៉ូប៊ីលីធី ហ្វាយនែន (ខេមបូឌា) ម.ក

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៦៧៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការតែងតាំង លោកជំទាវ ជា សិរី ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងអាជ្ញាបណ្ណគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុលេខ ភ.ហ.០០៧ ចុះថ្ងៃពុធ ៨រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា ដែលចេញឱ្យគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ម៉ូប៊ីលីធី ហ្វាយនែន (ខេមបូឌា) ម.ក និង
- យោងលិខិតលេខ មហក ០៤០/២៥ ចុះថ្ងៃចន្ទ ៨រោច ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥ របស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ម៉ូប៊ីលីធី ហ្វាយនែន (ខេមបូឌា) ម.ក

## សម្រេច

**ប្រការ ១.-**

ដកហូតអាជ្ញាបណ្ណគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុលេខ ភ.ហ.០០៧ ចុះថ្ងៃពុធ ៨រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា ដែលចេញឱ្យគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ម៉ូប៊ីលីធី ហ្វាយនែន (ខេមបូឌា) ម.ក (តទៅនេះហៅថា "គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ")។

**ប្រការ ២.-**

គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុត្រូវស្នើសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាក្នុងការជ្រើសតាំងអ្នកជម្រះបញ្ជីក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃប្រតិទិន គិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាលើប្រកាសនេះ។

ក្នុងករណី គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុខកខានក្នុងការតែងតាំងអ្នកជម្រះបញ្ជីបានត្រឹមកាលបរិច្ឆេទកំណត់ខាងលើ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុត្រូវទទួលស្គាល់អ្នកជម្រះបញ្ជី ដែលតែងតាំងដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៣.-**

អ្នកជម្រះបញ្ជីត្រូវមានសិទ្ធិអំណាចផ្តាច់មុខ ក្នុងការដឹកនាំ គ្រប់គ្រង និងតំណាងឱ្យគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ។

រាល់សិទ្ធិអំណាចរបស់ភាគទុនិក អភិបាល ឬអ្នកគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ត្រូវបានកម្រិតដោយលក្ខខណ្ឌ និងខថែង ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤.-**

រាល់ការចំណាយជាបន្ទុករបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុនិងត្រូវចាត់ទុកជាបំណុលរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុតាមលំដាប់នៃការជម្រះបញ្ជីតាមមាត្រា ៦៤ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៥.-**

ក្នុងករណីគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុមិនបានគោរពតាមការកំណត់ខាងលើ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុនឹងត្រូវប្រឈមនឹងការដាក់ទណ្ឌកម្មខាងវិន័យតាម មាត្រា ៥២ និង មាត្រា ៥៥ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៦.-**

អ្នកជម្រះបញ្ជីមានកាតព្វកិច្ចជម្រះទ្រព្យសកម្ម ទ្រព្យអកម្ម និងបំណុលរបស់គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា តាមសិទ្ធិនិងកាតព្វកិច្ច ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៧.-**

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបទប្បញ្ញត្តិនិងបរិយាបន្នហិរញ្ញវត្ថុ អគ្គនាយកប្រតិបត្តិការ អគ្គនាយកគោលនយោបាយនិងសហប្រតិបត្តិការអន្តរជាតិ អគ្គបេឡា អគ្គនាយកគ្រប់គ្រងសាច់ប្រាក់ អគ្គពិនិត្យ ប្រធាននាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ដែលមានការពាក់ព័ន្ធនឹងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ម៉ូប៊ីលីធី ហ្វាយនែន (ខេមបូឌា) ម.ក អ្នកជម្រះបញ្ជី ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២៥

**ទេសាភិបាល**

**ជា សិរី**

**កន្លែងទទួល៖**
- ដូច ប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៤៥០...

ថ្ងៃ...... ខែ...... ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...... ខែ...... ឆ្នាំ២០២៥

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥ របស់ក្រុមហ៊ុន អេ ធី អេស សូលូសិន ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អេ ធី អេស សូលូសិន ឯ.ក (ATS SOLUTIONS CO., LTD.) តំណាងដោយលោក **កាទ្រីភៀរ អ៊ីសប៉ាទ្រីក** (CATRY PIERRE YVES PATRICK) សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ 011274580 ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ បង្កើតរោងចក្រផលិតគ្រឿងអគ្គិសនី ដែលមានទីតាំងស្ថិតនៅផ្លូវលេខ១៧២៩ ភូមិត្រា៤ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| ប្រអប់ភ្លើង, បន្ទះប្រអប់ភ្លើង, បន្ទះសម្រាប់សិកខ្សែភ្លើង | ២៧៣៣ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតគ្រឿងអគ្គិសនី អេ ជី អេស សូលូសិន ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានទាប់ហើសអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ១២៦ ឧវបន.កឧ.ប្រក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ និងលិខិតលេខ៥៥១៦ ឧវបន.កឧ.លស ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការប្តូរនាមករណ៍ និងប្តូរប្រធានក្រុមប្រឹក្សាភិបាល របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -ខុទ្ទកាល័យរដ្ឋមន្ត្រី
- -សាលារាជធានីភ្នំពេញ
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

បណ្ឌិត ទឹម សុីនី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ............

ថ្ងៃ............ ខែ............ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី............ ខែ............ ឆ្នាំ២០២៥

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគលេខ១៤៥៩/២២ ក.អ.ក ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ ស្តីពីការបង្កើតរោងចក្រផលិតសម្ភារៈប្រើប្រាស់ក្នុងផ្ទះ និងក្នុងការិយាល័យ (ពីក្រណាត់ និងក្រដាស) របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ៤១៧០/២៤ គ.វ.ក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការប្តូរទីតាំងរោងចក្រ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ របស់ក្រុមហ៊ុន គ្លរី ឡៃថ៍ (ខេមបូឌា) អ៊ិនធើណេសិនណល ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន គ្លរី ឡៃថ៍ (ខេមបូឌា) អ៊ិនធើណេសិនណល ឯ.ក **(GLORY LIGHT (CAMBODIA) INTERNATIONAL CO., LTD.)** តំណាងដោយលោក **WANG, CHENG-HUA** សញ្ជាតិចិន(តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ **352796699** ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ បង្កើតរោងចក្រ ផលិតសម្ភារៈប្រើប្រាស់ក្នុងផ្ទះ និងក្នុងការិយាល័យ (ពីក្រណាត់ និងក្រដាស) ដែលមានទីតាំងស្ថិតនៅ ភូមិក្រាំងធ្នង់ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| ១-សម្ភារៈប្រើប្រាស់ក្នុងផ្ទះ និងការិយាល័យ (ពីក្រណាត់) | ១៣៩២ |
| ២-សម្ភារៈប្រើប្រាស់ក្នុងផ្ទះ និងការិយាល័យ (ពីក្រដាស) | ១៧០៩ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតសម្ភារៈប្រើប្រាស់ក្នុងផ្ទះ និងក្នុងការិយាល័យ (ពីក្រណាត់ និងក្រដាស) គ្លរី ឡៃថ៍ (ខេមបូឌា) អ៊ិនដើណេសិនណល ឯ.ក** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា ១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ២១៩ ឧវបន.កឧ.ប្រក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២ និងលិខិតលេខ ៥៥៧៦ ឧវបន.កឧ.លស ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការប្តូរទីតាំងរោងចក្រ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តតាកែវ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រី

**រដ្ឋលេខាធិការ**

**បណ្ឌិត ទីខ ស៊ីនី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-សាលាខេត្តតាកែវ
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តតាកែវ "ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: ៤៧១ ឧវបន . ពក . ប្រក.....

ថ្ងៃ.ពុធ...៦កើត....... ខែស្រាពណ៍.. ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...៣០.... ខែ..កក្កដា.. ឆ្នាំ២០២៥

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១៤២១/៩៩ គ.វ.ក ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការវិនិយោគលើគម្រោងដាំស្វាយចន្ទី ដើមម៉ៃសាក់ ដំណាំកសិកម្មផ្សេងៗ និងរោងចក្រកែច្នៃ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ១០៣៤/២០ គ.វ.ក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ ស្តីពីការប្តូរមុខសញ្ញាវិនិយោគពី "ការដាំស្វាយចន្ទី ម៉ៃសាក់ និងដំណាំកសិកម្មផ្សេងៗ (ដូងប្រេង)" មក "ដាំដំណាំឈើហូបផ្លែ និងរោងចក្រកែច្នៃ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងលិខិតលេខ៤២៧៧/១៩ គ.វ.ក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩, លិខិតលេខ២៣៦០/២២ គ.វ.ក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២ និងលិខិតលេខ៤៨២២/២៤ គ.វ.ក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការប្តូរអភិបាលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្តូរវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥ របស់ក្រុមហ៊ុនផលិតម្សៅដំឡូងមី ចំកាត់

### សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ផលិតម្សៅដំឡូងមី ចំកាត់ (FLOUR MANUFACTURING CO., LTD.)** តំណាងដោយលោក **BUI DUC DUNG** សញ្ជាតិវៀតណាម កាន់លិខិតឆ្លងដែនលេខ **Q00491953** ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៤ បង្កើតរោងចក្រកែច្នៃផ្លែឈើ ដែលមានទីតាំងស្ថិតនៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ផ្លែឈើ (កែច្នៃផ្លែចេក) | ១០៣០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **"រោងចក្រកែច្នៃផ្លែឈើ ផលិតម្សៅជំឡូងមី ចំកាត់ "**

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១០៖</u>** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានទាប់ហើសអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១១៖</u>** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**<u>ប្រការ១២៖</u>** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**<u>ប្រការ១៣៖</u>** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**<u>ប្រការ១៤៖</u>** ប្រកាសបង្កើតរោងចក្រលេខ៥១៥ ឧវបន.កឧ.ប្រក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២, លិខិតលេខ១៩៤៥ ឧវបន.កឧ.លស ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៥ និងលិខិតលេខ៣០៦៦ ឧវបន.កឧ.លស ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៥ ស្តីពីការប្តូរអភិបាល របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចាត់ទុកជានិរាករណ៍។

**<u>ប្រការ១៥៖</u>** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្ទឹងត្រែង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

**<u>ប្រការ១៦៖</u>** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**បណ្ឌិត ទឹម ស៊ីនី**

**<u>ចម្លងជូន៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-ខុទ្ទកាល័យរដ្ឋមន្ត្រី
-សាលាខេត្តស្ទឹងត្រែង
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តស្ទឹងត្រែង
-រដ្ឋបាលស្រុកបុរីអូរស្វាយសែនជ័យ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី